**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ[1]

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/ លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖................................................

លេខទូរស័ព្ទ ៖....................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ~ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

<u>**កម្មវត្ថុ**</u>៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្តឹងចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់ឈ្មោះ X

<u>**យោង**</u>៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង

**ខ.១.** ស្តីពីអង្គហេតុ "**ខ.១.១**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ទាំងស្រុង ។

**ខ.២.** ស្តីពីអង្គហេតុសងប្រាក់មួយភាគ "**ខ.១.២**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្តឹង៖ ចុងចម្លើយទទួលស្គាល់នូវការប្រគល់ប្រាក់ឲ្យទៅដើមចោទចំនួន ១.០០០ (មួយពាន់) ដុល្លារមេរិកនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចំពោះអង្គហេតុក្រៅពីនេះ ចុងចម្លើយមិនទទួលស្គាល់ទេ។

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានប្រគល់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទ ប៉ុន្តែ ប្រាក់នេះ គឺជាការសងបំណុលផ្សេង ហើយមិនមែនជាការសងទៅលើសិទ្ធិលើបំណុលជាប្រាក់ដែលដើមចោទកំពុងទាមទារនៅក្នុងរឿងក្តីនេះទេ។ ពោលគឺ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១២ ចុងចម្លើយបានលក់នំធ្វើពីផ្លែឈើចំនួន ១០.០០០ កញ្ចប់ដែលសរុបទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឲ្យទៅដើមចោទ ហើយដោយសារតែដើមចោទបាននិយាយថា នៅក្នុងចំណោមនំ

ទាំងនោះ មាននំចំនួន ៥០០កញ្ចប់ដែលខូច ហើយមិនអាចយកមកលក់បានទេ ហេតុដូច្នេះហើយ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានបង់ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទជាថ្លៃសងការខូចខាតចំពោះទំនិញទាំងនោះ។[3]

**ខ.៣.** ស្ដីពីអង្គហេតុ "**ខ.២**" ដែលសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ។

ដូចដែលបានលើកឡើងនៅខាងលើ នៅក្នុងរឿងក្ដីនេះ ដោយសារតែអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចឡើង ដូច្នេះ ចុងចម្លើយមិនមានករណីយកិច្ចបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចទេ ។

## គ. អង្គហេតុតវ៉ា

### គ.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចុងចម្លើយបានលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[4]។

ពោលគឺ បើគិតចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០០៨ ដែលជាពេលកំណត់ត្រូវសងនៃប្រាក់កម្ចីក្នុងរឿងក្ដីនេះមក នាំឲ្យថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ដែលជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុត។ ចុងចម្លើយលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលខាងលើតាមរយៈឯកសារចម្លើយ។

[3] ដូចដើមចោទបានអះអាងនៅក្នុងពាក្យបណ្ដឹង ប្រសិនបើចុងចម្លើយទទួលស្គាល់ថា ដើមចោទបានទទួលការសងមួយផ្នែកនៃប្រាក់កម្ចីពីចុងចម្លើយ អង្គហេតុនោះ នឹងត្រូវក្លាយជាមូលហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣) ។ ហេតុនេះ ដើម្បីឲ្យគេទទួលស្គាល់នូវការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក្នុងនាមជាចុងចម្លើយ ចាំបាច់ត្រូវតែពន្យល់ឲ្យបានលម្អិតថា ប្រាក់ដែលសង គឺមិនមែនជាការសងមួយផ្នែកនៃប្រាក់កម្ចីទេ។

[4] អង្គហេតុចម្បងស្ដីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមាន ① ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១) ② អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគិតចាប់ពីពេលនោះបានកន្លងផុត (ក្រមរដ្ឋប្បវេណី មាត្រា ៤៨២) និង ③ ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ កថាខណ្ឌទី១)។ នៅក្នុងរឿងក្ដីនេះ ចំពោះចំណុច ① គូភាគីមិនមានវិវាទទេ ហើយដោយសារតែចំណុច ② និង ③ គឺជាអង្គហេតុដែលមានលក្ខណៈជាក់ស្ដែងចំពោះតុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី២) ហេតុនេះ ចុងចម្លើយមិនចាំបាច់បញ្ជាក់ភស្តុតាងស្ដីពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។

### គ.២. ការទូទាត់[5][6]

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក **(ភស្តុតាង $Y_1$)** និង បានប្រគល់រថយន្ត **(ភស្តុតាង $Y_2$)** ទៅឱ្យដើមចោទចំពោះថ្លៃលក់រថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនោះ ចុងចម្លើយបានដាស់តឿនឲ្យបង់ជាច្រើនលើកច្រើនសារ ប៉ុន្តែ ដើមចោទមិនបានបង់ទេ។

ក្នុងករណីតុលាការមិនទទួលស្គាល់អំពីការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ចុងចម្លើយបង្ហាញឆន្ទៈទូទាត់នូវទឹកប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនៃសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញខាងលើនេះជាមួយនឹងកាតព្វកិច្ចប្រាក់កម្ចីក្នុងចំនួនសមស្រប។

**ដូច្នេះ ចុងចម្លើយមិនមានករណីកិច្ចបង់ប្រាក់ដើម និង ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យានៃរឿងក្តីនេះឲ្យដើមចោទទេ។**

---

[5] ការអះអាងនូវការតវ៉ាអំពីការទូទាត់ ចាំបាច់ត្រូវតែធ្វើការប្រុងប្រយ័ត្ន ដោយសារតែ គេព្រួយបារម្ភថា ការអះអាងនូវការតវ៉ា អំពីការទូទាត់នឹងនាំឲ្យមានការទទួលស្គាល់ អំពីការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ កថាខណ្ឌទី ៣) ទៅជាមួយគ្នា។ ប៉ុន្តែ ការតវ៉ាអំពីការទូទាត់នឹងនាំឲ្យកើតមានអានុភាពនៃអាជ្ញាអស់ជំនុំលើការវិនិច្ឆ័យនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ៤) ព្រមទាំងធ្វើឲ្យចុងចម្លើយខាតបង់ប្រយោជន៍ ជាងនៅពេលដែលតុលាការទទួលស្គាល់អំពីការតវ៉ាផ្សេងទៀត ដូច្នេះ ជាគោលការណ៍តុលាការគប្បីសម្រេចនូវការតវ៉ាអំពីការទូទាត់នៅក្រោយពេលមិនទទួលស្គាល់ទៅលើការតវ៉ាទាំងអស់ផ្សេងទៀត។ ដូច្នេះហើយ ទោះបីជាធ្វើការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និង អះអាងនូវការតវ៉ាអំពីការទូទាត់ក្នុងពេលជាមួយគ្នាក៏ដោយ ក៏គ្មានបញ្ហាដែរ។ ជាក់ស្តែង នៅក្នុងរឿងក្តីនេះ ក្នុងករណីដែលការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវតុលាការមិនទទួលស្គាល់ នាំឲ្យតុលាការនឹងត្រូវវិនិច្ឆ័យអំពីការតវ៉ា អំពីការទូទាត់។

[6] អង្គហេតុចម្បងនៃការទូទាត់ គឺ ① អត្ថិភាពនៃសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៤ កថាខណ្ឌទី ១ ) ② ការបង្ហាញឆន្ទៈអំពីការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៥ កថាខណ្ឌទី ១) ③ សិទ្ធិតវ៉ារបស់ភាគីម្ខាងទៀតទៅលើសិទ្ធិលើបំណុលដែលផ្តើមការទូទាត់ មិនទាន់បានភ្ជាប់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៨ កថាខណ្ឌ ទី១) ។ អង្គហេតុចម្បងនៃកិច្ចសន្យាលក់ទិញ ខណៈពេលដែលមានការអះអាងអំពីសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញធ្វើជាសិទ្ធិលើបំណុលដែលផ្តើមការទូទាត់នៅក្នុងរឿងក្តីនេះ គឺ ការព្រមព្រៀងអំពីកម្មវត្ថុ និង ប្រាក់ថ្លៃលក់ទិញ (ក្រមរដ្ឋប្បវេណី មាត្រា ៥១៥ និង មាត្រា ៥១៦) ។ ម្យ៉ាងវិញទៀត ដោយសារតែមានការភ្ជាប់នូវសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នារបស់អ្នកទិញ (មាត្រា ៥៥៨ កថាខណ្ឌទី ១) ចំពោះសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញ ខណៈពេលដែលចុងចម្លើយជាអ្នកលក់បានលើកឡើងអំពីការតវ៉ា ហេតុនេះ តាមភាពជាក់ស្តែង គឺមានភាពចាំបាច់ក្នុងការអះអាងអំពី ការបានប្រគល់រថយន្ត ។

**ឃ. ភស្តុតាង**

**១.**លិខិតកិច្ចសន្យាទិញលក់រថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ **(ភស្តុតាង$Y_1$)**

**២.**លិខិតប្រគល់ទទួលរថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ **(ភស្តុតាង$Y_2$)**

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤

**អ្នកតំណាងដោយអាណត្តិ**

B

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"